## អេម៉ាន្វែអែល

សំលេងពីព្រះសហគមន៍កាតូលិក

FM: 91 Mhz ខេត្តបាត់ដំបង

៧:៣០ នាទី រៀងរាល់ល្ងាចថ្ងៃសៅរ៍

FM: 88 Mhz ខេត្តកំពង់ធំ

១២:៣០- ១:៣០ នាទី រៀងរាល់ល្ងាចថ្ងៃសៅរ៍

FM: 102.5 Mhz ខេត្តសៀមរាប

១០:០០-១១:០០ នាទី រៀងរាល់ថ្ងៃសៅរ៍

## ការិយាល័យផ្សព្វផ្សាយព័ត៌មាន ព្រះសហគមន៍ កាតូលិក រតនះ

- បំលែងឯកសារពី VHS ទៅ DVD ទៅ VCD
- បំលែងចំរៀងពី កាសែតចម្រៀង ទៅ CD
- បង្កើតឯកសារវីឌីអូ សំរាប់ លោកឪពុក បងស្រី បងប្រុស។

ទំនាក់ទំនង ០៩២ ៦០៩ ៨៤៨

## ព័ត៌មានប្រចាំខែ ភូមិភាគ បាត់ដំបង

- ថ្ងៃសៅរ៍ ទី៣១ ឧសភា នៅព្រះសហគមន៍ប៉ោយប៉ែត បានរៀបចំកម្មវិធីជួបជាមួយអាណាព្យាបាលសិស្ស ដែលបានទទួលអារូបករណ៍ពីព្រះសហគមន៍ ចំនួន១០០ នាក់ នៅសាលាព្រៃគុក។
- ថ្ងៃអង្គារ៍ ទី១៥ ឧសភា មានការប្រជុំក្រុមម៉ាជីស (Magiss) នៅព្រះសហគមន៍ និគម។
- ថ្ងៃសៅរ៍ ទី១៩ ឧសភា នៅព្រះសហគមន៍ពោធិ៍សាត់ មានក្រុមគ្រូពេទ្យដែលមកពីប្រទេស សាំងហ្គាពួ បានចុះមកព្យាបាលប្រជាជន និងពិគ្រោះជំងឺទូទៅ ដោយឥតគិតថ្លៃផងដែរ។

## ល្បែងកំសាន្ត

សូមគូសតាមលេខដៃរសត្វស្រមោចលីខាងក្រោមនេះ



សូមស្វែងរកផ្លូវទៅផ្ទះរបស់អ្នក



Apostolic Prefecture of Battambang Monthly News. For Internal Circulation

# រតនះ RATTANAK

មហាគ្រួសារព្រះសហគមន៍ កាតូលិក Our Family

ព័ត៌មានព្រះសហគមន៍កាតូលិក ភូមិភាគបាត់ដំបង ប្រចាំខែ ឧសភា ឆ្នាំ ២០១២ លេខ ៣៩



## បងប្អូន ៣៥នាក់បានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ

មាតិកា

- ព្រះនាងម៉ារីជាទីពំនឹងគ្រីស្តបរិស័ទ ទំព័រ ២
- លោកអភិបាល ទេពអ៊ឹមសុត្ថា ជាគំរូដល់គ្រីស្តបរិស័ទ ទំព័រ ៦
- សិក្ខាសាលាស្តីអំពីកម្មវិធី ដំណើរការនៃគម្រោង ទំព័រ ៤-៥

ទំព័រ ៣

# ព្រះនាងម៉ារីជាទីពំនឹងគ្រីស្តបរិស័ទ


Photo: An RittyRath

ដោយៈ មុយ សាម៉េត

**ជាការពិតណាស់ ព្រះនាងម៉ារី ជាមាតាដ៏ល្អ ដែលមានចិត្តសណ្តោះប្រណី និងមានធម៌មេត្តាករុណា ដែលអាចអោយយើងជាគ្រីស្តបរិស័ទ យកព្រះនាងជាទីពំនឹងក្នុងការរស់នៅប្រចាំថ្ងៃ។ ហើយក្នុងនាមយើងជាគ្រីស្តបរិស័ទ សូមយកគំរូតាមព្រះនាង និងដើររួមគ្នាជាមួយព្រះនាងតាមអំពើល្អ។**

គ្រីស្តបរិស័ទទូទាំងពិភពលោកបានចាត់ទុកព្រះនាងម៉ារីជាទីពឹង និងជាជំនួយក្នុងការរស់នៅប្រចាំថ្ងៃ។ ដោយហេតុនេះហើយបានជានៅព្រះសហគមន៍ កាតូលិកបាត់ដំបង បានប្រារព្ធបុណ្យព្រះនាងម៉ារីជាទីពឹងនេះឡើងដើម្បី លើកតម្កើនព្រះនាងម៉ារី ជាមាតារបស់ព្រះយេស៊ូ កាលពីថ្ងៃច័ន្ទ ទី២៤ ខែឧសភា ឆ្នាំ២០១២ ដោយមានក្រុមរបស់បងស្រី លក្ខណា ជាអ្នកគ្រប់គ្រងមណ្ឌល សាលេសៀន ជាអ្នករៀបចំបុណ្យនេះឡើង។ បុណ្យនោះមានក្បួនដង្ហែពីមុខផ្ទះលោកអភិបាល ឆ្ពោះទៅកាន់ព្រះវិហារ ដើម្បីថ្វាយអភិបូជា។ ម្យ៉ាងវិញទៀតនាឱកាសបុណ្យនោះ ជាការអប់រំអរសាទរដល់បងស្រី លក្ខណា ដែរបងស្រីបានបម្រើការងារនៅក្នុងប្រទេស កម្ពុជា អស់រយះពេល១០ ឆ្នាំផងដែរ។ ក្នុងពេលនោះដែរលោកឪពុក តូតេត បានមានប្រសាសន៍ក្នុងការបកស្រាយព្រះគម្ពី ដែរថា “ព្រះនាងម៉ារីជាមួយក្នុងដំណើរជីវិតរបស់គ្រីស្តបរិស័ទ ហើយព្រះនាងបានដឹងពីតម្រូវការរបស់យើងទាំងអស់គ្នា ដោយព្រះនាងបានអោយព្រះយេស៊ូ ប្រទាននូវតម្រូវការនោះ”។ លោកឪពុកបានបន្តទៀតថា “បុណ្យនេះមានសារៈសំខាន់ណាស់ សម្រាប់បងស្រីសាលេសៀន ពីព្រោះក្រុមបងស្រីសាលេសៀន ទូទាំងពិភពលោកបានយករូបព្រះនាងម៉ារី ជាឧបកានារី ដូចច្នេះយើងចូលរួមជាមួយបងស្រីសាលេសៀន សូមយកព្រះនាងម៉ារីជាទីពំនឹងរបស់យើង”។ ពេលបញ្ចប់កម្មវិធីអភិបូជា បងស្រីបានចែករូបព្រះនាងម៉ារីជាមួយព្រះយេស៊ូនិងបណ្តោងព្រះនាងម៉ារីដល់គ្រីស្តបរិស័ទមួយម្នាក់ៗទៀតផងដែរ។ ព្រះនាងម៉ារី ជាប្រភព ដែរគ្រីស្តបរិស័ទយកធ្វើជាទីពឹង និងយកជាគំរូ ដោយចេះប្រើចិត្តមេត្តាករុណា ដល់អ្នកដ៏ទៃ។





# សន្តី ថេរេសា នៅក្រុង លីស៊ីយឺ

**ក្នុងរតនះលេខមុន យើងបានស្គាល់ សន្តី ថេរេសា នៅក្រុង លីស៊ីយឺ រីឯលេខនេះគឺ យើងបន្តអាននូវប្រវត្តិ របស់សន្តី ថេរេសា បន្តទៀត។ តើ ថេរេសា យល់យ៉ាងដូចម្តេចអំពើខ្លួនឯង? តើ ថេរេសា ស្រលាញ់ព្រះជាម្ចាស់យ៉ាងណា ហើយព្រះជាម្ចាស់នឹងប្រគល់អ្វីអោយទៅនាងវិញ? ដូចនេះ សូមអានក្នុងអត្ថបទខាងក្រោមនេះទាំងអស់គ្នា។**



៖«អ្នកបួសកាន់តមធម៌ ដើម្បីឲ្យអ្នកបាបកែប្រែចិត្តគំនិត និងចាកចេញពីបាប ដែលគេបានប្រព្រឹត្តចំពោះព្រះជាម្ចាស់។ ម៉្យាងទៀតធម៌របស់យើង ធ្វើឲ្យព្រះជាម្ចាស់ផ្អាកទណ្ឌកម្មចំពោះអ្នកបាប»។ នាង ថេរេសា ឆ្លើយថា ៖«កុំរវល់មើលបាបខ្លួនឯងពេក!ក្រែងលោយើងមើលធម៌មេត្តាករុណារបស់ព្រះ យេ៉ស៊ូ មិនឃើញ។ ម៉្យាងទៀតតមធម៌មេត្តាករុណារបស់ ព្រះជាម្ចាស់ហាក់បីដូចជាភ្លើង នៃធម៌មេត្តាករុណារំលាយបាប របស់នាងខ្ញុំចោលទាំងអស់ដូច្នេះនាងខ្ញុំ អត់ឃើញស្នាមបាបរបស់ខ្ញុំទៀតទេ»។ សន្តីថេរេសាយល់ថា ៖«នាងខ្ញុំមិនអាចសន្សំបុណ្យកុសល នៃតបធម៌បានទេ ពីព្រោះនាងខ្ញុំជាមនុស្សសាមញ្ញធម្មតា ដែលមានតែដង្វាយតូចតាចចំពោះព្រះអង្គប៉ុណ្ណោះ។ នាងខ្ញុំចេះតែស្រលាញ់ព្រះជាម្ចាស់ដ៏សប្បុរសហើយ ព្រះជាម្ចាស់នឹងតបសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ដ៏សប្បុរសហើយព្រះជាម្ចាស់នឹងតបសេចក្តីស្រលាញ់មកនាងខ្ញុំវិញជាពុំខាន។ ម៉្យាងទៀត ពេលនាងខ្ញុំនៅតែធ្វើអំពើដ៏សប្បុរសដើម្បីនឹងជួយបងប្អូននៅលើផែនដី។ ផ្លូវដ៏តូចតាចរបស់នាងខ្ញុំ គឺនាងខ្ញុំចង់បានចិត្តដូចកូនក្មេងជានិច្ច ដ្បិតក្មេងៗតែងតែទុកចិត្តមាតាបិតា រហូតព្រមទាំងនាំឲ្យមាតាបិតាមានអំណរសប្បាយ ដោយឃើញកូនធ្វើកិច្ចការដ៏តូចតាចចំពោះគាត់។ ហើយកិច្ចការដ៏តូចតាច ធ្វើឲ្យមាតាបិតាមានអំណរខ្លាំងជាងនៅពេលកូនធំ និងធ្វើកិច្ចការដ៏យាប់លំបាក! ហេតុនេះហើយបានជានាងខ្ញុំទុកចិត្តលើព្រះជាម្ចាស់ជានិច្ច ព្រមពេលនាងកើតជម្ងឺយ៉ាងវេទនា នាងបានតែង ពាក្យថ្វាយខ្លួនទៅព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ នៅថ្ងៃទី០៩ ខែ ០៦ ឆ្នាំ១៨៩៥ ដូចតទៅ ៖ឱ!ព្រះជាម្ចាស់នៃទូលបង្គំអើយ! ឱព្រះត្រៃអង្គ!ព្រះអង្គពោរពេញដោយសុភមង្គល នាងខ្ញុំសុំស្រលាញ់ព្រះអង្គ ហើយចង់ធ្វើឲ្យមនុស្សឯទៀតៗស្រលាញ់ព្រះអង្គផង(...)។ នាងខ្ញុំចង់គាប់ព្រះហឫទ័យព្រះជាម្ចាស់ឲ្យបានគ្រប់លក្ខណ(...) គឺសូមឲ្យនាងខ្ញុំទៅជាសន្តីម្នាក់។ នាងខ្ញុំយល់ថាខ្ញុំមិនអាចធ្វើខ្លួនឯងបានទេបាន.......(តលេខក្រោយ)

# លោកអភិបាល ទេពអ៊ឹមសុត្ថា ជាគំរូដល់គ្រីស្តបរិស័ទ

ដោយៈ អាន ឫទ្ធីរដ្ឋ

**ក្នុងនាមយើងជាគ្រីស្តបរិស័ទ ត្រូវរក្សាជំនឿអោយបានខ្ជាប់ខ្ជួន នឹងរឹងមាំ ហ៊ានធ្វើសាក្សី ដែលយកគំរូល្អពីព្រះយេស៊ូ។ ដើរតាមមាគ៌ារបស់ព្រះអង្គ យកអំពើល្អរបស់ព្រះអង្គ ដាក់ក្នុងចិត្ត និងអធិដ្ឋានជាមួយព្រះអង្គគ្រប់ពេល។ ការស្រលាញ់ សេចក្តីអាណិត ធម៌មេត្តា ជាមាគ៌ារបស់ព្រះអង្គ។**



Photo: An Rittyrath

កាលពីថ្ងៃច័ន្ទ ទី០៧ ខែឧសភា ឆ្នាំ ២០១២ នៅដីមរណៈសាក្សីនៃព្រះសហគមន៍ កាតូលិកស្វាយស៊ីសុផុន បានប្រារព្ធវិញ្ញាណក្ខន្ធលោកអភិបាល ទេពអ៊ឹម សុត្ថា យ៉ាងឱឡារិក។ កម្មវិធីបុណ្យនេះបានប្រារព្ធឡើង ក្នុងគោលបំណងចង់អោយគ្រីស្តបរិស័ទស្គាល់លោកអភិបាល ទេពអ៊ឹមសុត្ថា និងយកគម្រូតាមលោកអភិបាល ក្នុងការរស់នៅប្រចាំថ្ងៃ។ ខណៈពេលនោះដែរ មានបងប្អូនគ្រីស្តបរិស័ទ បានចូលរួមក្នុងពិធីបុណ្យនេះ ក្នុងនោះមានបងប្អូនមកពីព្រះសហគមន៍ បាត់ដំបង ប៉ៃលិន សៀមរាប តាហែន ស្វាយស៊ីសុផុន ផ្ទាល់ ព្រមទាំងមានមណ្ឌលអារ៉ូពេ មណ្ឌលសាលេសៀន និងមណ្ឌលផ្សេងៗផងដែរ។ ក្នុងកម្មវិធីបុណ្យទាំងមូលនោះ មានលោកអភិបាល គីគេ លោកបូជាចារ្យចំនួន ៨អង្គ បានរួមគ្នាថ្វាយអភិបូជាក្នុងបុណ្យនោះផងដែរ។ ស្របពេលនោះដែរលោកបូជាចារ្យ តូតេត បានបកស្រាយព្រះគម្ពីរទាក់ទងនឹងជីវិតរបស់លោកអភិបាល ទេពអ៊ឹម សុត្ថាផងដែរថា "ក្នុងសាសនាគ្រីស្តយើងគឺមរណៈសាក្សីគឺជាសាក្សី ដែលបានលះបង់ជីវិតដោយសារជំនឿនិងធ្វើអំពើល្អជាច្រើនចំពោះព្រះយេស៊ូគ្រីស្ត"។ លោកបានមានប្រសាសន៍ថា "មរណៈសាក្សីបានធ្វើឲ្យយើងមានជំនឿកាន់តែរឹងមាំ ព្រោះយើងបានមើលឃើញនូវជំនឿ ដ៏អស្ចារ្យដែលបានលះបង់ជីវិតហេតុនេះ សូមបងប្អូនទាំងអស់គ្នាយកចិត្តទុកដាក់ពីរបៀបធ្វើជាសាក្សីរបស់ព្រះ យេស៊ូ ដោយធ្វើអំពើល្អចំពោះអ្នកដ៏ទៃ"។ ពេលអភិបូជាក៏មានការសម្តែងរឿង អំពីជីវប្រវត្តិរបស់លោកទេពអ៊ឹមសុត្ថា ផងដែរ។ អ្នកស្រីដាំ ប្រាជ្ញា បានឡើងមានប្រសាសន៍ថា "លោកអភិបាល ទេពអ៊ឹម ជាអភិបាលមួយអង្គដែលគួរអោយយើងស្រលាញ់ ហើយមិនអាចបំភ្លេចបាន ព្រោះលោកបានប្រម៉ែប្រ–មូលបងប្អូនគ្រីស្តបរិស័ទ នាំគ្នាអធិដ្ឋានរៀងរាល់ថ្ងៃអាទិត្យ ហើយអ្វីជាពិសេសនោះ គឺលោកក៏បានហៅប្តីប្រពន្ធទាំងអស់មកបង្រៀនក្នុងការរស់នៅ ជាគ្រួសារដ៏ល្អផងដែរ"។ ក្នុងកម្មវិធីបុណ្យនោះបានធ្វើឲ្យជំនឿរបស់បងប្អូនគ្រីស្តបរិស័ទ ទាំងអស់កាន់តែរឹងមាំ ដោយបានមើលឃើញនូវការលះបង់ជីវិតរបស់លោកអភិបាល ទេពអ៊ឹម សុត្ថា។ ពិធីបុណ្យនេះបានបញ្ចប់ទៅដោយល្អប្រសើរ ដោយមានការរាំកំសាន្ត និងទទួលទានរួមគ្នាផងដែរ។



Photo: An Rittyrath

# បងប្អូន ៣៥នាក់បានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ



Photo: An RittyRath

ដោយៈ មុយ សាម៉េត

ក្នុងឱកាសបុណ្យព្រះវិញ្ញាណយាងមក បងប្អូនជាគ្រីស្តបរិស័ទ មានចិត្តសប្បាយរីករាយ ដោយព្រះជាម្ចាស់បានប្រទាននូវព្រះវិញ្ញាណថ្មីដ៏រុងរឿង ដល់ព្រះយេស៊ូ ដើម្បីជួយព្រះសហគមន៍ និងបំភ្លឺផ្លូវ ទាំងចិត្តគំនិត របស់បងប្អូនគ្រីស្តបរិស័ទ និងជាកំលាំងកាយចិត្ត ដល់គ្រីស្តបរិស័ទទាំងអស់ផងដែរ។ ជាពិសេសកាលពីព្រឹកថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១២ ព្រះសហគមន៍ កាតូលិក បាត់ដំបង បានប្រារព្ធពិធីបុណ្យព្រះវិញ្ញាណយាងមក យ៉ាងឱឡារិក។ ទន្ទឹមនិងនេះ ក៏មានបងប្អូនគ្រីស្តបរិស័ទ ចំនួន ៣៥នាក់ ដែលព្រះវិញ្ញាណបានត្រាស់ហៅ អោយពួកគាត់ទទួលអគ្គសញ្ញាលាបថ្ងាស។ គោលបំណងនៃអគ្គសញ្ញាលាបថ្ងាសគឺ ចង់បញ្ជាក់ថាអ្នកដែរបានទទួលអគ្គសញ្ញានេះ និងក្លាយជាគ្រីស្តបរិស័ទ ដែលហ៊ានធ្វើជាសាក្សី និងសក្ខីភាពចំពោះព្រះជាម្ចាស់ដើម្បីផ្សាយដំណឹងល្អដល់មនុស្សទាំងអស់ អោយបានស្គាល់ព្រះអង្គកាន់តែច្បាស់។ ក្នុងនោះដែរ បងប្អូនដែលទទួលអគ្គសញ្ញាលាបថ្ងាស ទាំង ៣៥នាក់ បានអញ្ជើញមកពីទីកន្លែងខុសៗគ្នាដូចជា ព្រះសហគមន៍ តាអំ ច្រាបវាល ប៉ោយប៉ែត ខ្នាចរមាស ស្វាយស៊ីសុផុន និងព្រះសហគមន៍ បាត់ដំបង ផងដែរ។ ស្របពេលនោះដែរ លោកអភិបាល គីគេ បានមានប្រសាសន៍ ពន្យល់ និងណែនាំដល់បងប្អូនទាំង ៣៥នាក់ យ៉ាងដូច្នេះថា "ខ្ញុំសូមនិយាយចំពោះបងប្អូន ដែលនឹងទទួលអគ្គសញ្ញាលាបថ្ងាស។ ខ្ញុំមានបួនចំនុចចង់និយាយប្រាប់បងប្អូនដែល និងក្លាយខ្លួនជាគ្រីស្តបរិស័ទ នោះចំនុចទីមួយ យើងត្រូវស្រលាញ់ព្រះជាម្ចាស់ ដោយការអធិដ្ឋាន និងចំនុចទីពីរគឺ ការអធិដ្ឋានពិចារណាអំពីជីវិតនូវកំហុសខុសឆ្គង និងចំនុចទីបីគឺ ការអធិដ្ឋានដោយការអានព្រះគម្ពីរដោយខ្លួនឯង ហើយចំនុចក្រោយទីបួន គឺបង្ហាញសេចក្តីស្រលាញ់ និងអំពើល្អក្នុងការរស់នៅ ដែលបង្ហាញពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់"។ លោកឪពុកបានបន្តទៀតថា "នេះជាការបង្ហាញមាគ៌ារបស់ព្រះអង្គអោយពួកយើងស្គាល់ ពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ តាមរយៈព្រះយេស៊ូ"។ ក្នុងនោះអ៊ុំស្រី ច្រឹក នាង អាយុ ៥៧ឆ្នាំ ដែលមកពីព្រះសហគមន៍ ច្រាបវាល បានមានប្រសាសន៍ថា "ខ្ញុំបានរៀនអប់រំជំនឿអស់រយៈពេលប្រាំឆ្នាំ ហើយចំណែកឯជំនឿរបស់ខ្ញុំវិញ ក៏រឹងមាំដែរ។ សម្រាប់ថ្ងៃនេះ ខ្ញុំក៏មានចិត្តសប្បាយរីករាយ ដែលបានទទួលអគ្គសញ្ញាលាបថ្ងាស ដែរបញ្ជាក់ថាខ្ញុំជាគ្រីស្តបរិស័ទយ៉ាងពេញលេញ"។ ចំណែកឯកញ្ញា កន ស៊ីយ៉ា អាយុ ២២ឆ្នាំ បាននិយាយពីជំនឿរបស់ខ្លួនប្រាប់រតនៈយើងដែរថា "ក្នុងរយៈពេលដែលនាងខ្ញុំបានរៀនអប់រំជំនឿ ជាមួយលោកគ្រូ អ្នកគ្រូមក បានធ្វើអោយចិត្តនាងខ្ញុំមានការគិតគូរវែងឆ្ងាយ ដែលពីមុនចិត្តខ្ញុំតែងតែមានចិត្តមួយ ដែលវិនាស និងមិនចេះអត់អន់អ្នកដទៃទេ ប៉ុន្តែនៅពេលដែលបានចូលរៀនអប់រំជំនឿ ដោយទទួលបានការណែនាំ ពីលោកគ្រូ អ្នកគ្រូ ជាពិសេសមានលោកឪពុក ដែលចាំជួយផ្តល់យោបល់ដល់រូបនាងខ្ញុំ"។ កញ្ញាបានបន្តទៀតថា "នៅក្នុងថ្ងៃនេះ ខ្ញុំមានចិត្តសប្បាយរីករាយមែនទែន ពីព្រោះនេះជាជីវិតថ្មី ដែលរូបខ្ញុំក្លាយខ្លួនជាគ្រីស្តបរិស័ទពេញលេញ ហើយខ្ញុំនឹងត្រូវមានភារកិច្ចពីព្រះជាម្ចាស់ ទៅផ្សព្វផ្សាយដំណឹងល្អដល់អ្នកដ៏ទៃ និងចេះជួយសង្គ្រោះគេផងដែរ"។ ចុងក្រោយនៃពិធីអគ្គសញ្ញាលាបថ្ងាស ពិតជាមានភាពសប្បាយរីករាយផងដែរ។



Photo: An RittyRath

**កម្មវិធិជប់លាងរបស់ក្រុមការងារការីតាសនៅព្រះសហគមន៍ កាតូលិក បាត់ដំបង កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១២។ កម្មវិធីនេះមានការចូលរួមពីសំណាក់លោកអភិបាល គឺគេ លោកបូជាចារ្យ និងក្រុមការងារផងដែរ។ កម្មវិធីនេះក៏មានការសំដែងរបាំបែបប្រពៃណីខ្មែរ និងការសំដែងក្បួចរាំតៃក្វាន់ដូ របស់ព្រះសហគមន៍ បាត់ដំបង ជូនភ្ញៀវទស្សនានារាត្រីនោះដែរ។**



Photo: An RittyRath

**ក្រុមសិស្ស ដែលទទួលអាហារូបករណ៍ពីព្រះសហគមន៍បាន ចុះទៅនិទានរឿងនៅក្នុងភូមិ ដែលសិត្ថនៅភូមិស្រែមួយពាន់ កាលពីថ្ងៃអាទិត្យ ទី២៧ ខែឧសភា ឆ្នាំ២០១២។ ការចុះទៅនេះ ក្នុងគោលបំណងដើម្បីលេងជាមួយក្មេងៗ និងសួរសុខទុក្ខដល់ពួកគេផងដែរ។ ការចុះរបស់សិស្សអាហារូបករណ៍នេះ ធ្វើឡើងជារៀងរាល់ថ្ងៃអាទិត្យ។ នេះក៏ជាការទំនាក់ទំនងរវាងយុវជន និងកុមារដែលរស់នៅក្នុងភូមិ។**

# សិក្ខាសាលាស្តីអំពីកម្មវិធីដំណើរការនៃគម្រោង ( Program Planning Facts )

ដោយ: មុយ សាម៉េត

រាល់ការងារតែងតែមានគម្រោងទុកជាមុនដើម្បីសម្រេចនូវរាល់កិច្ចការ ដែលព្រៀងទុក។ ប៉ុន្តែបើគ្មានការធ្វើគម្រោងទុកជាមុនទេ នោះប្រាកដជាមានផលវិបាកជាក់ជាពុំខានសម្រាប់ការងារ ដែលនិងគ្រោងទុក។

កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១២ នៅព្រះសហគមន៍ បាត់ដំបង មានរៀបចំសិក្ខាសាលាមួយដែលស្តីអំពីកម្មវិធីដំណើរការនៃគម្រោង (Program Planning Facts)។ កម្មវិធីនេះមានការចូលរួមពីបងប្រុស ប្លាស់ និងសិស្សមណ្ឌល ទេពអ៊ុម ដែលជាអ្នកសម្របសម្រួល និងសិស្សដែលទទួលអាហារូបករណ៍សរុបប្រមាណ ១៨នាក់ ដែលបានចូលរួមនៅក្នុងសិក្ខាសាលានេះ។ គោលបំណងនៃសិក្ខាសាលានេះធ្វើឡើងដើម្បីអោយ សិស្ស និងអ្នកដែរ មានការងារយល់ដឹងអំពីសារៈសំខាន់នៃការធ្វើគម្រោង ដោយមានភាពច្បាស់លាស់ក្នុងការធ្វើទុកជាមុនដែលផ្តល់ភាពងាយស្រួលរាល់កិច្ចការងារនៃគម្រោងនីមួយៗ។ ស្របពេលនោះដែរបងប្រុស ប្លាស់ បានបង្ហាញនូវប្រាំមួយចំនុច ដែលទាក់ទង នឹងការធ្វើគម្រោង ក្នុងនោះយើងសូមលើកយកពីរចំនុច ដែលសំខាន់យកមកសរសេរ នៅលើសារៈព័ត៌មាននេះ។ ចំនុចទីមួយ គឺជាការនិយាយអំពីលក្ខណៈនៃការបង្កើតគម្រោងក្នុងការប្រើប្រាស់រយៈពេល ចំនុចនេះបញ្ជាក់ពីការតាមដានរាល់ហេតុការណ៍កើតឡើង និងជាក់លាក់។ ចំនែកឯចំនុចទីពីរ គឺជាការនិយាយអំពីគម្រោងរបស់យើង នៃតំរូវការរបស់មនុស្ស ចំនុចនេះ ចង់ផ្តោតទៅលើរាល់បញ្ហាដែលកើតមាន ចំពោះមនុស្សគ្រប់រូបដែរជួបប្រទះ។ ដូច្នេះការធ្វើគម្រោងទុកជាមុនពិតជាផ្តល់ភាពងាយស្រួល ក្នុងការងារដែលយើងចង់បានទទួលភាពជោគជ័យនៃការសម្រេច រាល់របាយការណ៍នានា។ ជាចុងក្រោយក៏មានការចែករំលែកនូវចំណេះដឹងដែលបានទទួលពីសិក្ខាសាលានេះ។



Photo: Moy Samet

Photo: An Rittyrath



**ផ្ទាក់ដូរ្យតន្ត្រីពេទ្យយាយជី ដែលមានឈ្មោះហៅកាត់ថា (PMP) បានចាប់ផ្តើមទទួលសិស្សថ្មីអោយចូលរៀនហើយ។ នេះបញ្ជាក់អោយឃើញថា យុវជន បានចំណាយពេលដែលមានប្រយោជន៍ ជាមួយ និងទេពកោសល្យរបស់ពួកគេក្នុងការលេងតន្ត្រី ដោយពួកគេមិនចំណាយពេល ដែលឥតប្រយោជន៍ និងធ្វើអោយសង្គមស្អប់ខ្ពើម។ PMP បានចូលរួមចំនែកផ្តល់ជំនាញ ដល់ពួកគេក្នុងការលេងតន្ត្រី រីពួកគេអាចយកជំនាញនេះយកទៅប្រើប្រាស់សម្រាប់ចិញ្ចឹមជីវិតទៅថ្ងៃមុខៗ។**

# កីឡាជាចំណងមិត្តភាព



Photo: An RittyRath

នៅលើជុំវិញពិភពលោកទាំងអស់តែងតែមានការទំនាក់ទំនងគ្នាដោយការទូត ឬទំនាក់ទំនងតាមអ្វីផ្សេងៗទៀត ដែលអាចធ្វើបាន។ ប៉ុន្តែទៀតសោត យើងមិនអាចមើលរំលងកីឡាបានទេពីព្រោះកីឡាជាប្រភេទ ដែលធ្វើអោយមនុស្សគ្រប់រូបមានសុខភាពល្អ មានប្រាជ្ញាវាងវៃ ដែលចង់អោយយើងលេងក្នុងកីឡានេះ។ម្យ៉ាងវិញទៀត កីឡាដែលគេពេញនិយមលេង នឹងមានគាំទ្រច្រើននោះ គឺជាកីឡាបាល់ទាត់។ កីឡាបាល់ទាត់ជាប្រភេទកីឡាមួយ ដែលយុវជន យុវនារី មិនថាចាស់ឬក្មេង ចូលចិត្តលេង និងតាមដានទស្សនារាល់ការប្រកួតធំៗ នៅគ្រប់ជុំវិញពិភពលោក ហើយកីឡានេះមាននៅលើគ្រប់តំបន់ មិនថានៅអាស៊ីយើង ឬក៏នៅអឺរ៉ុបឡើយ។ ដូច្នេះហើយបានជាព្រះសហគមន៍ កាតូលិក បាត់ដំបង តែងតែមានការរៀបចំ ការប្រកួតបាល់ទាត់ក្នុងគោលបំណងចង់អោយយុវជន បានស្គាល់គ្នា និងដកស្រង់បច្ចេកទេសជាមួយគ្នាទៅវិញទៅមក។ ដូចនេះហើយ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១២ នៅព្រះសហគមន៍ កាតូលិក បាត់ដំបង មានការប្រកួតបាល់ទាត់ជាលក្ខណៈមិត្តភាព រវាងក្រុមមណ្ឌល មាតុភូមិកុមារ ជាមួយ និងក្រុម កាតូលិកបាត់ដំបង ដើម្បីដកស្រង់បច្ចេកទេសផងដែរ។ ជាលទ្ធផលក្រុម កាតូលិបាត់ដំបង បានយកឈ្នះលើ ក្រុមមណ្ឌល មាតុភូមិកុមារ ដោយប្រភិតប្រភើយ។ នេះបញ្ជាក់ថា កីឡាក៏ជាការទូតនាំមកនៅចំណងមិត្តភាព ដែលបានផ្តល់អោយយុវជន និងយុវជន បានស្គាល់គ្នាតាមរយៈការលេងកីឡាបាល់ទាត់នេះ។

**ដោយ: មុយ សាម៉េត**